# បទអន្តរាគមន៍
# របស់តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
# នៅក្នុងពិធីប្រកាសជាផ្លូវការនៃការដាក់ឱ្យអនុវត្ត
# កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី ២
# របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**ឯកឧត្តម លោកជំទាវ អស់លោក និង លោកស្រី ជាទីគោរព និងរាប់អាន !**

ថ្ងៃនេះ តាងនាមឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខ្ញុំមានកិត្តិយស និងក្តីសោមនស្សរីករាយជាទីបំផុត ដែលបានចូលរួមក្នុងពិធីប្រកាសជាផ្លូវការនៃការដាក់ឱ្យអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី ២ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ហើយក៏សូមវាយតម្លៃខ្ពស់ចំពោះការយកចិត្តទុកដាក់របស់ក្រសួង ដែលបានចូលរួមយ៉ាងសកម្មនៅក្នុងការរៀបចំផែនការសកម្មភាពកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី ២ ។

ដូចឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ជ្រាបស្រាប់ហើយថា កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺជាកម្មវិធីកែទម្រង់ដែលមានចក្ខុវិស័យរយៈពេលវែងច្បាស់លាស់មានលក្ខណៈគ្រប់ជ្រុងជ្រោយ និងប្រទាក់ក្រឡាគ្នា មានគោលបំណងច្បាស់លាស់ មានផែនការសកម្មភាពជាក់ស្តែង និងអនុវត្តតាមយុទ្ធសាស្ត្រជាជំហានៗ និងទៅតាមដំណាក់កាលនីមួយៗ ព្រមទាំងមានក្របខណ្ឌត្រួតពិនិត្យតាមដានវឌ្ឍនភាពយ៉ាងទៀងទាត់ និង ម៉ត់ចត់ ។ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល មាន ៤ ដំណាក់កាល គឺ ការបង្កើនភាពជឿទុកចិត្តបាននៃថវិកា ការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ និងគណនេយ្យភាពចំពោះសមិទ្ធកម្ម ។ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល ត្រូវបានប្រកាសជាផ្លូវការដាក់ឱ្យអនុវត្តដំណាក់កាលទី ១ នៅថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០០៤ និង ដំណាក់កាលទី ២ នៅថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៨ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ។

ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី ១ ពីឆ្នាំ ២០០៤ ដល់ឆ្នាំ ២០០៨ រាជរដ្ឋាភិបាលសម្រេចបានលទ្ធផលជាច្រើន ដូចជា (១) បានកែលម្អ និង ពង្រឹងការគ្រប់

គ្រងចំណូល តាមរយៈ ការបង្កើតឱ្យមានម៉ូដែលព្យាករណ៍ម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ ការរៀបចំគោលនយោបាយចំណូលរយៈពេលមធ្យម និង ការកែលម្អរដ្ឋបាលប្រមូលចំណូល ដែលជាលទ្ធផលចំណូលក្នុងស្រុកជាមធ្យមបានកើនឡើងក្នុងរង្វង់ ២៦% ចាប់ពីឆ្នាំ ២០០៥ (២) បានកែលម្អ និង ពង្រឹងការរៀបចំថវិកា តាមរយៈ ការកែលម្អដំណើរការនៃការរៀបចំថវិកា ការដាក់ឱ្យអនុវត្តការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និង ការអនុវត្តសាកល្បងថវិកាកម្មវិធី (៣) បានកែលម្អ និង ពង្រឹងការអនុវត្តថវិកា តាមរយៈ ការកាត់បន្ថយនីតិវិធីចំណាយ ការបង្កើតឱ្យមានអង្គភាពគ្រប់គ្រងសាច់ប្រាក់ ការដាក់ឱ្យអនុវត្តគណនីទោលរតនាគារ ការធ្វើវិសហមជ្ឈការលទ្ធកម្មសាធារណៈ និង ការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់ថវិកា និង ប្លង់គណនេយ្យថ្មី និង (៤) បានពង្រឹង និងកសាងសមត្ថភាពមន្ត្រី តាមរយៈ ការផ្តល់នូវវគ្គសិក្សារយៈពេលខ្លី និងវែង និងការធ្វើទស្សនៈកិច្ចសិក្សាទៅក្រៅប្រទេស ។ លទ្ធផលទាំងអស់នេះ គឺជាស្នូលដែលនាំឱ្យសម្រេចបាននូវទិសដៅកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី ១ គឺ ***ភាពជឿទុកចិត្តបាននៃថវិកា*** ដោយបានប្រែក្លាយស្ថានភាពហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាលពីភាពពុំរឹងនៃឱនភាពសាច់ប្រាក់មកជាអតិរេកសាច់ប្រាក់ ។

**ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី !**

កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី ២ មានទិសដៅបន្តពង្រឹងភាពជឿទុកចិត្តបាននៃថវិកា បង្កើនគណនេយ្យភាពចំពោះការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង រៀបចំមូលដ្ឋានសម្រាប់ផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ដើម្បីសម្រេចបានទិសដៅនេះ ផែនការសកម្មភាពរួមរបស់រាជរដ្ឋាភិបាលត្រូវបានរៀបចំឡើងជាមួយនឹងការកំណត់គោលដៅសូចនាករច្បាស់លាស់ ។

គ្រប់ក្រសួង-ស្ថាប័នទាំងអស់ ត្រូវរៀបចំផែនការសកម្មភាពរបស់ខ្លួនប្រកបដោយម្ចាស់ការ និងការទទួលខុសត្រូវរៀងៗខ្លួនឱ្យស្របតាមផែនការសកម្មភាពរួម ដើម្បីរួមចំណែកសម្រេចឱ្យបាននូវគោលដៅសូចនាកររួមរបស់រាជរដ្ឋាភិបាល ។ ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី ២ ក្រសួង-ស្ថាប័ន ទាំងអស់ ត្រូវដើរតួជាតួអង្គគន្លឹះក្នុងការអនុវត្ត គឺទាមទារឱ្យមានការចូលរួមយ៉ាងសកម្មប្រកបដោយភាពជាម្ចាស់ និង ការទទួលខុសត្រូវខ្ពស់ គឺមិនដូចដំណាក់កាលទី ១ ដែលការងារភាគច្រើនប្រមូលផ្តុំនៅក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នោះទេ ។

ដើម្បីឆ្លើយតបទៅនឹងការពង្រីកវិសាលភាពនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី ២ នេះ ការរៀបចំយន្តការដឹកនាំ គ្រប់គ្រង និង សម្របសម្រួល គឺជាប្រការសំខាន់

និងចាំបាច់ ដោយរាជរដ្ឋាភិបាលបានកែលម្អគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានបង្កើតគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានបង្កើតក្រុមការងារបច្ចេកទេសកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ និង បានបង្កើតអនុគណៈកម្មាធិការ គណៈកម្មការ និងក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅតាមក្រសួង-ស្ថាប័ន ។

**ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី !**

ឆ្លងតាមបទពិសោធន៍ដែលទទួលបាននៅក្នុងដំណាក់កាលទី ១ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមចែករំលែកនូវបទពិសោធន៍ ដើម្បីធានាបាននូវភាពជោគជ័យនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដល់គ្រប់ក្រសួង-ស្ថាប័នទាំងអស់ ដែលរួមមាន (១) ត្រូវមានយន្តការសម្របសម្រួល និងតាមដានការអនុវត្តផែនការសកម្មភាពទាំងនៅផ្ទៃក្នុងក្រសួង-ស្ថាប័ន និងផ្ទៃក្នុងអង្គភាពក្រោមឱវាទ (២) ត្រូវមានឆន្ទៈ ការប្តេជ្ញាចិត្ត និងការចូលរួមយ៉ាងសកម្មពីសំណាក់ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញ (៣) ត្រូវមានយន្តការច្បាស់លាស់ក្នុងការប្រើប្រាស់ជំនួយបច្ចេកទេសដើម្បីផ្ទេរចំណេះដឹង និងចំណេះធ្វើឱ្យដល់មន្ត្រីជំនាញ (៤) ត្រូវរៀបចំផែនការអភិវឌ្ឍន៍ធនធានមនុស្ស តាមរយៈវគ្គបណ្តុះបណ្តាល និង ទស្សនកិច្ចសិក្សារយៈពេលខ្លី និង វែងទាំងក្នុង និងក្រៅប្រទេស និង (៥) ផ្តល់ការលើកទឹកចិត្តដល់មន្ត្រីដែលមានសមត្ថភាព ជាដើម ។

ជាថ្មីម្តងទៀត តាងនាមឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ និង សូមកោតសរសើរដោយស្មោះចំពោះការការខិតខំប្រឹងប្រែងយ៉ាងសកម្ម និងពុះពារគ្រប់ឧបសគ្គរបស់ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីរាជការទាំងអស់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលបានចូលរួមយ៉ាងសកម្មនៅក្នុងការរៀបចំផែនការសកម្មភាពកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង ផ្តល់ការសហការយ៉ាងជិតស្និទ្ធដើម្បីគាំទ្រដល់ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល ។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរដល់ឯកឧត្តម លោកជំទាវ អស់លោក និង លោកស្រី ប្រកបដោយសុខភាពល្អ កម្លាំងពលំមាំមួន និង សម្រេចបានជោគជ័យដ៏ត្រចះត្រចង់ក្នុងគ្រប់ភារកិច្ច ដើម្បីបុព្វហេតុជាតិមាតុភូមិ និង ការអភិវឌ្ឍ ។

**សូមអរគុណ !**